YUNNAN DAILY PRESS GROUP
No.161

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី 26 លេខ 7688 ថ្ងៃសុក្រ ទី20 ខែ កក្កដា ឆ្នាំ 2018

## ពិព័រណ៍វប្បធម៌ច្នៃប្រឌិតខេត្តយូនណានឆ្នាំ២០១៨



សម្លៀកបំពាក់ប្រពៃណីជនជាតិហ្វៃយ៉ាវ យី នៅពិព័រណ៍វប្បធម៌ ច្នៃប្រឌិតខេត្តយូនណាន កាលពីឆ្នាំទៅ (រូបថតដោយYang Zheng )

នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ ២០១៨ តាមប្រភពព័ត៌មានពីគណៈកម្មាធិការរៀបចំពិព័រណ៍បានឱ្យដឹងថា ពិព័រណ៍វប្បធម៌ច្នៃប្រឌិតខេត្តយូនណានឆ្នាំ២០១៨នឹងប្រារព្ធឡើងនៅមជ្ឈមណ្ឌលសន្និសីទនិងពិព័រណ៍អន្តរជាតិក្រុងគុនមីងក្នុងអំឡុងពេលពីថ្ងៃទី៩ដល់ទី១៣ ខែសីហា ឆ្នាំ ២០១៨ ។

គួរបញ្ជាក់ថា ក្នុងឱកាសពិព័រណ៍វប្បធម៌នេះ ពន្លាពិព័រណ៍ក្រុងគុនមីង នឹងផ្តោតសំខាន់ទៅលើប្រធានបទ "វប្បធម៌+បច្ចេកវិជ្ជា" ហើយនឹងរៀបចំតំបន់សាកល្បងសកម្មភាព "វប្បធម៌+បច្ចេកវិជ្ជា" ដើម្បីដាក់តាំងបង្ហាញនូវផលិតផលច្នៃប្រឌិតថ្មីមួយចំនួនរួមមានបច្ចេកទេស VR, AR, MR, Front-projected holographic display និងបច្ចេកទេសថតវីដេអូ៧២០ឌឺក្រេជាដើម។ ក្រៅពីនេះត្បូងពិសេសរបស់ខេត្តយូនណាននឹងត្រូវដាក់តាំងពិព័រណ៍ក្នុងពន្លាពិព័រណ៍ត្បូង និងរតនវត្ថុ ហើយនឹងរៀបចំពិព័រណ៍ស្នាដៃចម្លាក់យក់យូនណាន "ពានរង្វាន់ពពកចម្រុះពណ៌ឆ្នាំ២០១៨"។

ក្នុងឱកាសពិព័រណ៍នេះ វេទិកាជាន់ខ្ពស់ស្តីពីការអភិវឌ្ឍឧស្សាហកម្មវប្បធម៌តន្ត្រីជនជាតិភាគតិច "ខ្សែក្រវាត់មួយ និងផ្លូវមួយ" ខេត្តយូនណាន ប្រទេសចិន "ផ្លូវសូត្រ ចង្វាក់ភ្លេង" លើកទី១ នឹងត្រូវរៀបចំឡើងនៅខេត្តយូនណាន។ តន្ត្រីករ អ្នកកំណែទម្រង់ឧបករណ៍តន្ត្រី និងអ្នកសិក្សាស្រាវជ្រាវវប្បធម៌ល្បីឈ្មោះរបស់ប្រទេសចិនបានអញ្ជើញចូលរួម និងពិគ្រោះពិភាក្សាអំពីការអភិវឌ្ឍវប្បធម៌តន្ត្រីខេត្តយូនណានក្នុងវេទិកានេះ។ ទន្ទឹមនឹងនេះកម្មវិធីបង្ហាញម៉ូតសម្លៀកបំពាក់ផ្កាពិភពលោកឆ្នាំ២០១៨និងពន្លាពិព័រណ៍គំនិតច្នៃប្រឌិតរបស់កុមារក៏បានត្រូវរៀបចំនិងបង្ហាញជូនសាធារណជនជាលើកដំបូងក្នុង ពិព័រណ៍វប្បធម៌នេះ៕

**ដោយលី យូឈុន**

## ស្នាដៃរបាំចិនត្រូវសម្តែងនៅក្រុងគុនមីង



ផ្ទាំងរូបភាពមួយនៃ "ស្ថានីយរថភ្លើងទៅទីបេត៍" ដែលជារបាំមួយដែលបានសម្តែងនៅក្នុងអំឡុងពេល នៃពិធីបើកពិព័រណ៍របាំជាតិចិនលើកទី១២ (រូបថតដោយ Zhou Can )

កាលពីថ្ងៃទី១១ ដល់ទី២១ ខែកក្កដា ឆ្នាំ២០១៨ ពិព័រណ៍របាំទូទាំងប្រទេសចិនលើកទី១២ បានប្រារព្ធនៅក្រុងគុនមីង។ ពិព័រណ៍នេះជាពិព័រណ៍របាំសំខាន់ និងធំជាងគេក្នុងប្រទេសចិន រួមមានកម្មវិធីសម្តែងសិល្បៈចំនួន៨០ និងល្ខោនរបាំចំនួនប្រាំ ដែលបានធ្វើឱ្យទស្សនិកជនគ្រប់ៗគ្នាជក់ចិត្តដិតអារម្មណ៍យ៉ាងខ្លាំង។

ពិព័រណ៍នេះមិនគ្រាន់តែបានរៀបចំកម្មវិធីសម្តែងសិល្បៈដ៏ទាក់ទាញគ្រប់ប្រភេទប៉ុណ្ណោះទេ ថែមទាំងបានបង្ហាញនូវស្នាដៃរបាំមួយចំនួនដែលអាចបង្ហាញពីសមិទ្ធផលនៃការធ្វើកំណែទម្រង់ និងបើកចំហ ព្រមទាំងប្រកបដោយស្មារតីចិនបែបបទចិន និងរចនាបថចិន ។ អ្វីដែលគួរឱ្យបញ្ជាក់នោះគឺកម្មវិធីសម្តែងសិល្បៈចំនួនប្រាំពីររបស់ខេត្តយូនណានបានត្រូវជ្រើសរើសឱ្យទៅសម្តែងក្នុងឱកាសពិព័រណ៍នេះ រួមមានល្ខោនរបាំ របាំសម្តែងដោយមនុស្សម្នាក់ និងរបាំសម្តែងដោយមនុស្សបីនាក់ ដែលបានបង្ហាញឱ្យឃើញពីលក្ខណៈពិសេស និងកម្លាំងទាក់ទាញផ្នែកសិល្បៈនៃរបាំជនជាតិភាគតិចរបស់ខេត្តយូនណាន៕

## រូបមន្ត "ទិញទំនិញផ្ទាល់" ធ្វើឱ្យភូមិជនជាតិលីស៊ូទទួលការរីកចម្រើនគួរឱ្យកត់សម្គាល់

ភូមិស៊ីប៉ាឃុំជនជាតិលីស៊ូ សៀយូ ស្រុកតឺឈានមណ្ឌលស្វយ័តជនជាតិទីបេត៍ទីឈាង ខេត្តយូនណានមានទីតាំងស្ថិតនៅក្នុងតំបន់ស្នូលនៃតំបន់អភិរក្សធម្មជាតិភ្នំព្រឹលប៉ៃម៉ា ។ ទីនេះជាមូលដ្ឋានហៀបនិងកន្លែងបន្តពូជរបស់សត្វនិងរុក្ខជាតិដ៏កម្រឃើញជាច្រើនប្រភេទ ។ ប៉ុន្តែដោយសារទីនេះមានហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ហើយមានបរិស្ថានមិនអំណោយផលដល់ការរស់នៅរបស់មនុស្សដូច្នេះ ក្នុងចំណោមគ្រួសារទាំង៣០២នៅភូមិស៊ីប៉ា មានគ្រួសារចំនួន២៥៩ ជាគ្រួសារក្រីក្រ ។

ពេលថ្មីៗនេះសហគ្រិន និងអ្នកជំនាញការ៣០រូប ដែលធ្វើអាជីវកម្ម និងសិក្សាស្រាវជ្រាវអំពីកសិផលពិសេសបានទៅធ្វើការសិក្សានៅក្នុង ភូមិស៊ីប៉ាក្រោមការរៀបចំពីមន្ទីរ ហិរញ្ញវត្ថុមណ្ឌលទីឈាងដើម្បីពិគ្រោះ ពិភាក្សាអំពីការដោះស្រាយបញ្ហាប្រឈម និងជំរុញការអភិវឌ្ឍនៃភូមិស៊ីប៉ាព្រមទាំងធ្វើឱ្យភូមិជនជាតិ លីស៊ូជៀស ផុតពីបញ្ហាក្រីក្រក្នុងពេល ឆាប់ៗ ។

លោកប៉ៃ ជីឡុងប្រធានគណៈកម្មការអាជីវកម្មផលិតផលពិសេសយូនណាននៃតំបន់បង្កើតមុខជំនួញពាណិជ្ជកម្មបណ្តាញអ៊ីនធើណេតក្រុងយីអ៊ូប្រទេសចិនបានគូសបញ្ជាក់ថា ក្រុមការងាររបស់យើងខ្ញុំបានទៅធ្វើការសិក្សាជាក់ស្តែងនៅភូមិស៊ីប៉ាដើម្បីបង្កើតជារូបមន្តកាត់បន្ថយភាពក្រីក្រថ្មីមួយដែលអាស្រ័យលើការអភិវឌ្ឍមុខរបរថ្មីដោយផ្តោតសំខាន់ទៅលើរូបមន្ត "ការណែនាំពីរដ្ឋាភិបាល+ធនធានដ៏មានឧត្តមភាព+ការគ្រប់គ្រងគុណភាព+ការបង្កើតម៉ាកល្បី+ការផ្សព្វផ្សាយតាមទីផ្សារ+ការទិញទំនិញដោយផ្ទាល់"។

ក្រុមហ៊ុនបច្ចេកវិទ្យាយូនស្វូប៉ាវខេត្តយូនណានបានចេញសេចក្តីសម្រេចថា ជារៀងរាល់ឆ្នាំក្រុមហ៊ុននឹងទិញយកផ្សិតសុងយ៉ុងស្រស់៥០តោនពីភូមិស៊ីប៉ាដើម្បីផ្សព្វផ្សាយនិងជញ្ជូនអាហារពិសេសក្នុងតំបន់ភ្នំនេះជូនចំពោះអតិថិជនដោយផ្ទាល់ហើយបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការបញ្ជាទិញផ្សិតសុងយ៉ុងដែលមានតម្លៃស្មើនឹង១០លានយាន់នៅថ្ងៃដដែលនោះ ។

វិទ្យាស្ថានសិក្សាស្រាវជ្រាវ-អាស៊ីខាងត្បូងនៃបណ្ឌិត្យសភាវិទ្យា-សាស្ត្រខេត្តយូនណាននិងសមាគមពិនិត្យគុណភាពខេត្តយូនណានបានធ្វើការសិក្សាស្រាវជ្រាវនិងពិគ្រោះពិភាក្សាអំពីការអភិវឌ្ឍមុខរបរឱសថចិនការដាំផ្លែឈើ ការថែរក្សាអេកូ-បរិស្ថាននិងការអភិវឌ្ឍទេសចរណ៍តាមតំបន់ជនបទជាដើម ដើម្បីប្រមូលផ្តុំនូវក្តីប្រាថ្នានិងកម្លាំងប្រជាជនសម្រាប់ជំរុញការកាត់បន្ថយភាពក្រីក្រនិងការអភិវឌ្ឍដោយចីរភាព ។

លោកយូ ខាងលេខាធិការប្រចាំការដើម្បីជួយកាត់បន្ថយភាពក្រីក្រនៅភូមិស៊ីប៉ាដែលមកពីមន្ទីរហិរញ្ញវត្ថុមណ្ឌលទីឈាងបានលើកឡើងថា នៅពេលខាងមុខផលិតផល ពិសេសរបស់ភូមិជនជាតិលីស៊ូនឹងអាចក្លាយទៅជាកម្លាំងចលករសម្រាប់កាត់បន្ថយភាពក្រីក្រ ។ ក្នុងរយៈពេល៣ឆ្នាំកន្លងទៅនោះ លោកបានទទួលការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះបម្រែបម្រួលនៃភូមិស៊ីប៉ា ៕

**ដោយយ៉ាង ជុងយូវ(ស៊ីនហួចិន)**

## ប្រធានសមាគមខ្មែរចិននៅកម្ពុជា:បង្កើតស្ពានតភ្ជាប់ក្រអៅបេះដូងរវាងប្រជាជនកម្ពុជា និងចិន

ក្នុងឱកាសអបអរសាទរខួបលើកទី៦០នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសចិននិងកម្ពុជា លោកឧកញ៉ា ពុងខៀវសែ ប្រធានសមាគមខ្មែរចិននៅប្រទេសកម្ពុជា បានផ្តល់បទសម្ភាសន៍ជាមួយអ្នកសារព័ត៌មាននាថ្ងៃទី៧ ខែកក្កដា ក្នុងរាជធានីភ្នំពេញថា ក្នុងនាមជាចំណងខ្សែដ៏សំខាន់មួយសម្រាប់ពង្រឹងចំណងមិត្តភាពកម្ពុជានិងចិន សមាគមខ្មែរចិននៅកម្ពុជានឹងបន្តរួមចំណែកក្នុងការបង្កើនការផ្លាស់ប្តូរផ្នែកវប្បធម៌និងពាណិជ្ជកម្មរវាងប្រទេសទាំងពីរដើម្បីពង្រឹងចំណងមិត្តភាពជាប្រពៃណីរវាងប្រទេសទាំងពីរកម្ពុជានិងចិន ។

លោកឧកញ៉ាបានមានប្រសាសន៍ថា សមាគមខ្មែរចិនជាសមាគមអាណិកជនចិនធំជាងគេនៅប្រទេសកម្ពុជាដែលបានទាក់ទាញកម្លាំងអាណិកជនចិននិងជនជាតិចិនដ៏ឆ្នើមនៅប្រទេសកម្ពុជាដើម្បីរួមវិភាគទានក្នុងការតភ្ជាប់ផ្នែកវប្បធម៌និងក្រអៅបេះដូងរវាងប្រជាជននៃប្រទេសទាំងពីរ ។

នៅពេលនិយាយចំពោះប្រវត្តិ-សាស្ត្រនៃទំនាក់ទំនងមិត្តភាពរវាងប្រទេសកម្ពុជានិងចិនលោកឧកញ៉ាបានរំលឹកឡើងវិញថា ចំណងមិត្តភាពកម្ពុជានិងចិនមានប្រវត្តិសាស្ត្រយូរលង់ណាស់មកហើយ ។ មិត្តភាពកម្ពុជា-ចិនដែលរួមគ្នាបង្កើតនិងពូនជ្រំដោយអ្នកដឹកនាំជំនាន់ចាស់របស់ប្រទេសទាំងពីរបានឆ្លងកាត់ការសាកល្បងនៃបម្រែបម្រួលស្ថានការណ៍អន្តរជាតិហើយកាន់តែមានភាពរឹងមាំថែមទៀត ។ ឆ្នាំនេះជាខួបលើកទី៦០នៃការបង្កើតទំនាក់ទំនងការទូតកម្ពុជានិងចិន ។ ភាគីទាំងពីរបាននិងកំពុងពង្រឹងនិងពង្រីកឱ្យកាន់តែស៊ីជម្រៅនូវកិច្ចសហ-ប្រតិបត្តិការលើគ្រប់វិស័យដែលបាននាំមកនូវផលប្រយោជន៍ជាក់ស្តែងដល់ប្រជាជននៃប្រទេសទាំងពីរ ។

លោកឧកញ៉ាបន្តទៀតថាកម្ពុជាជាប្រទេសមួយដែលបានរក្សាស្ថិរភាពកម្រិតខ្ពស់ជាងគេក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅតំបន់អាស៊ីអាគ្នេយ៍ ហើយមានតម្រូវការចំពោះទុនវិនិយោគបរទេស ចំណែកប្រជាជនខ្មែរមានតម្រូវការបន្ទាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងកែលម្អជីវភាពរស់នៅ ។ ខ្ញុំសង្ឃឹមថា សហគ្រាសនិងវិនិយោគិនកម្ពុជានិងចិននឹងអាចរួមគ្នាជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនៃប្រទេសទាំងពីរអាស្រ័យលើលក្ខខណ្ឌអំណោយផលនាពេលបច្ចុប្បន្ន ។

លោកឧកញ៉ាបានសង្កត់ធ្ងន់ថា អាណិកជនចិននៅកម្ពុជាមានភាពឧស្សាហ៍ព្យាយាមនិងចិត្តស្មោះត្រង់ ហើយគោរពតាមពាក្យសន្យារបស់ខ្លួន និងមានភាពឈ្លាសវៃ ។ ក្នុងរយៈពេលយ៉ាងយូរអង្វែងកន្លងទៅនោះអាណិក-ជនចិននៅកម្ពុជាបានទទួលការជឿទុកចិត្តពីសំណាក់ប្រជាជនខ្មែរ ។ ប៉ុន្មានឆ្នាំមកនេះអាណិកជនចិនដែលទៅធ្វើវិនិយោគនៅប្រទេសកម្ពុជាបាននាំមកនូវហិរញ្ញប្បទានបច្ចេកទេស និងបទពិសោធន៍ដល់ប្រទេសកម្ពុជា ។ ខ្ញុំជឿថា ចំណងមិត្តភាពជាប្រពៃណីរវាងប្រទេសទាំងពីរនឹងអាចត្រូវពង្រឹង និងពង្រីកឱ្យកាន់តែល្អប្រសើរថែមទៀតពីមួយថ្ងៃទៅមួយថ្ងៃ ៕

ដោយម៉ៅ ភឹងហ្វី

## ខេត្តយូនណានប្រកាសខ្សែបន្ទាត់ក្រហមអំពីការការពារអេកូ-ធម្មជាតិ



រូបថតនៃភ្នំព្រិលទឹកកក បាយម៉ា ដែលស្ថិតនៅភាគពាយ័ព្យ នៃខេត្តយូនណាន (រូបថតដោយChen Fei )

ពេលថ្មីៗនេះ សាលារដ្ឋបាលខេត្តយូនណានបានប្រកាសជាផ្លូវការនូវ "ខ្សែបន្ទាត់ក្រហមអំពីការការពារអេកូ-ធម្មជាតិ"។ តាមលិខិតផ្លូវការនេះបានឱ្យដឹងថា "ខ្សែបន្ទាត់ក្រហមអំពីការការពារអេកូ-ធម្មជាតិ" ខេត្តយូនណាន បានគ្របដណ្តប់លើផ្ទៃក្រឡា ១១,៨៤ម៉ឺនគីឡូម៉ែត្រការ៉េ ស្មើនឹង៣០,៩ភាគរយនៃទំហំសរុបរបស់ខេត្តយូនណាន។

"ខ្សែបន្ទាត់ក្រហមអំពីការការពារអេកូ-ធម្មជាតិ" របស់ខេត្តយូនណានរួមមាន "រនាំងបី និងខ្សែ ក្រវាត់ពីរ" ។ "រនាំងបី" គឺរនាំងអេកូ-ធម្មជាតិភាគខាងត្បូងខ្ពង់រាបទីបេត៍ និងជ្រលងភ្នំខ្ពស់ភាគពាយ័ព្យរនាំងអេកូ-ធម្មជាតិភ្នំអៃឡាវ-អ៊ូលាំង និងរនាំងអេកូ-ធម្មជាតិព្រៃឈើតំបន់ព្រំដែន ខាងត្បូង។ "ខ្សែក្រវាត់ពីរ" គឺខ្សែក្រវាត់ទន្លេជីនសាទន្លេឡានឆាង ទន្លេហុងហឺ និងខ្សែក្រវាត់សណ្ឋានដីខាសត៍នៅភាគអាគ្នេយ៍។

ក្នុងតំបន់អភិរក្សធម្មជាតិ "ខ្សែបន្ទាត់ក្រហម" នេះ មានសត្វ និងរុក្ខជាតិដ៏កម្រឃើញជាច្រើនដែលបានទទួលនូវការអភិរក្សថ្នាក់ខេត្ត និងថ្នាក់ជាតិ រួមមានសត្វស្វារោមមាសយូនណាន ខ្លារខិនយូនណាន ក្ងោកបៃតង និងដើមឈើកម្រមានមួយចំនួនធំ ៕

**ដោយហ្វ៊ូ សៀវយ៉ុង**